មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍
# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រារព្ធកម្មវិធីរំលឹកខួបប្រាំបួនឆ្នាំនៃមរណភាព
# លោកបណ្ឌិត កែម ឡី

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២៥

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») នឹងប្រារព្ធកម្មវិធីរំលឹកខួបប្រាំបួនឆ្នាំនៃមរណភាពលោកបណ្ឌិត កែម ឡី ជាអ្នកវិភាគនយោបាយដ៏ល្បីល្បាញ និងសកម្មក្នុងការតស៊ូមតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា។ លោកបណ្ឌិត កែម ឡី ធ្លាប់ជាសមាជិកក្រុមប្រឹក្សាភិបាលនៃ ម.ស.ម.ក ចាប់ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៤ ផងដែរ។ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់យ៉ាងអាណោចអាធ័មទាំងកណ្តាលថ្ងៃនៅស្ថានីយប្រេងឥន្ធនៈមួយកន្លែងក្នុងរាជធានីភ្នំពេញ។ ដើម្បីរំលឹកខួបប្រាំបួនឆ្នាំនៃមរណភាពលោកបណ្ឌិត ម.ស.ម.ក នឹងរៀបចំសកម្មភាពតាមអនឡាញ និងនៅការិយាល័យរបស់ខ្លួន ដូចខាងក្រោម៖

- ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី០៧ ខែកក្កដា ម.ស.ម.ក នឹងបង្ហោះសម្រង់សម្តីសំខាន់ៗរបស់លោកបណ្ឌិត កែម ឡី នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។
- នៅថ្ងៃទី០៤ ខែកក្កដា ម.ស.ម.ក នឹងផ្សាយផ្ទាល់កម្មវិធីវិទ្យុក្រោមប្រធានបទ «រយៈពេល៩ឆ្នាំនៃឃាតកម្មលើលោកបណ្ឌិត កែម ឡី និងការចងចាំរូបលោក»។
- នៅថ្ងៃទី០៧ ខែកក្កដា នឹងប្រារព្ធពិធីបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធលោកបណ្ឌិត នៅការិយាល័យ ម.ស.ម.ក ។
- នៅថ្ងៃទី១០ ខែកក្កដា នឹងផ្សព្វផ្សាយវីដេអូចំណងជើងថា «វិភាគទានរបស់លោកបណ្ឌិត កែម ឡី ដើម្បីសង្គមប្រជាធិបតេយ្យកម្ពុជា» នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។
- នៅថ្ងៃទី១៧ ខែកក្កដា នឹងផ្សព្វផ្សាយវីដេអូចំណងជើងថា «ការចងចាំ» នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក ហួន ផន អ្នកសម្របសម្រួលគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា នៃម.ស.ម.ក តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ ០៧០ ៧៥៧ ៨៨៤ ៕

– ចប់ –

**<u>បណ្ណាធិការៈ</u>**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») បង្កើតឡើងក្នុងឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អែស អូ អែស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រឹសបេន ប្រទេសអូស្ត្រាលី៕